# យ៉ូរ៉ានី
# និងស្រីងបៃតង

## ការណែនាំសម្រាប់សកម្មភាពថ្នាក់រៀន





### វិនាដកម្ម (ល្ខោន)

សិស្សានុសិស្សអាចធ្វើការជាក្រុម ដើម្បីបង្កើតរឿងល្ខោនដោយផ្អែកទៅលើសាច់រឿងក្នុងសៀវភៅ។ ក្មេងៗនឹងធ្វើសំលៀកបំពាក់ ឬរបាំងមុខអោយដូចទៅនឹងចរិកតួនៅក្នុងសៀវភៅដូចជា ស្រីងបៃតង ឪម៉ាល់ប៉ារ៉ាស៊ីត ឬរុយប៉ារ៉ាស៊ីត។ នៅខណៈពេលដែលបង្កើតរឿងល្ខោន និងសម្តែងរឿង វាផ្តោតអារម្មណ៍របស់សិស្សានុសិស្ស ហើយវាគួរតែមានការពិភាក្សានៅក្នុងថ្នាក់ជាមុន ដើម្បីកំណត់ព័ត៌មានកសិកម្មសំខាន់ៗ ដែលគួរតែបញ្ចូលវាទៅក្នុងការសម្តែងរបស់ពួកគេ។

### ការសំដែងតុក្កតា

ការសំដែងតុក្កតាដោយដៃងាយៗនៃស្រីងមានប្រយោជន៏ និងស្រីងចង្រៃអាចត្រូវបានធ្វើឡើងជំនួសការស្លៀកពាក់សំលៀកបំពាក់ និងរបាំងមុខ។ វាអាចត្រូវបានធ្វើឡើងដោយប្រើសម្ភារៈអ្វីក៏បានដែលអាចរកបាន។ បន្ទាប់មក ក្រុមសិស្សនីមួយៗអាចសំដែងជាតួអង្គតុក្កតានៃស្រីងមានប្រយោជន៏ និងស្រីងចង្រៃ។

### ចម្រៀង

ក្មេងៗអាចតែងបទកាព្យខ្លីៗពីសាច់រឿង ហើយច្រៀង ឬសូត្របទកាព្យទាំងនោះជាមួយនឹងបទភ្លេងនៃចម្រៀងដែលពេញនិយម។

### សុន្ទរកថា

ក្មេងៗអាចរៀបចំសុន្ទរកថាខ្លីមួយ អំពីវិធានការចម្រុះគ្រប់គ្រងកត្តាចង្រៃ (អាយភីអឹម – IPM) ដោយផ្អែកទៅលើអ្វីដែលពួកគេបានរៀនពីសៀវភៅ។

### សៀវភៅសត្វល្អិត

សិស្សានុសិស្សអាចបង្កើតសៀវភៅសត្វល្អិតដោយផ្ទាល់ខ្លួនរបស់ពួកគេ ឬធ្វើការងារនេះរួមគ្នាដើម្បីបង្កើតសៀវភៅធំមួយនៅក្នុងថ្នាក់ ដែលអាចត្រូវបានយកទៅតម្កល់នៅក្នុងបណ្ណាល័យរបស់សាលា។ ពួកគេអាចគូរចម្លងចេញពីសៀវភៅនៅលើទំព័រ១៨-១៩ ហើយបន្ទាប់មកដាក់ស្លាកឈ្មោះវា និងពណ៌នាដោយសង្ខេបពីក្រោម ថាតើហេតុអ្វីបានជាពួកវាល្អ ឬអាក្រក់សម្រាប់ដំណាំ។ សកម្មភាពនេះអាចត្រូវបានពង្រីកដោយបញ្ចូលព័ត៌មានបន្ថែមទៅលើការស្រាវជ្រាវសត្វល្អិតផ្សេងៗទៀតដោយសិស្សានុសិស្ស។



ACIAR
www.aciar.gov.au







## ការដាក់តាំងបិតិវត្ត និងគំរូ

គំរូបិតិវត្តនៃសត្វល្អិតផ្សេងៗនៅក្នុងសៀវភៅ អាចត្រូវបានធ្វើពីសម្ភារៈផ្សេងៗ ។ គំរូទាំងនេះអាចត្រូវបានដាក់តាំងនៅឯថ្នាក់រៀនពិសេសមួយ ឬព្រឹត្តិការណ៍ពិសេសរបស់សាលា ដែលមានផ្ទាំងក្រដាសនៅជាប់ម្ខាងសម្រាប់អោយអ្នកទស្សនាផ្តល់ជាមតិយោបល់របស់ពួកគេ ។ ការផ្តល់រង្វាន់ពិសេសសម្រាប់ករណីដូចជាមើលទៅមានសភាពរស់រវើក ពិពណ៌នាបានក្បោះក្បាយ ការរៀបចំដាក់តាំងបានល្អប្រសើរ ។ល ។ អាចត្រូវបានបង្កើតឡើងដោយសិស្សានុសិស្ស និងធ្វើការផ្តល់រង្វាន់នៅពេលចុងបញ្ចប់នៃកម្មវិធី ។

## ការប្រមូលសត្វល្អិត

កំប៉ុង ឬប្រអប់ប្លាស្ទិកសម្រាប់ដាក់ម្ហូបអាហារ អាចត្រូវបានប្រើសម្រាប់ប្រមូលសត្វល្អិតនៅតាមផ្ទះ ។ សត្វល្អិតអាចត្រូវបានសម្លាប់ដោយអាល់កុល ហើយដោតនឹងម្ជុល និងដាក់ក្នុងប្រអប់សម្រាប់ដាក់តាំងបង្ហាញ ។ ការប្រមូលសត្វល្អិតអាចអោយបានត្រឹមត្រូវតាមដំណាក់កាលលូតលាស់ផ្សេងៗនៃស្រឹងបៃតង ព្រមទាំងសត្វល្អិតមានប្រយោជន៏ផងដែរ ។

## សួនសាលា

សួនសាលានៃដំណាំអន្ទាក់ និងដំណាំជម្រកដែលមើលថែទាំដោយក្មេងៗ អាចជាវិធីសាស្រ្តក្នុងការអនុវត្តមួយដើម្បីបង្ហាញនូវគំនិតខ្លះរបស់អាយភីអឹម (IPM) ។ សកម្មភាពអាចមានដូចជាការអង្កេតតាមដាន និងការរាប់ចំនួនសត្វល្អិតចង្រៃ និងសត្វរំពារ (ប្រេដាទ័រ) នៅលើដើមរុក្ខជាតិក្នុងសួន ។ ស្រឹងមានប្រយោជន៏ អាចត្រូវបានលែងទៅក្នុងដំណាំជម្រកជាភ្នាក់ងារកំចាត់មួយដ៏ប្រសើរតាមបែបជីវសាស្រ្ត ។

## ប័ណ្ណប្រកាសអាយភីអឹម **(IPM poster)**

ក្មេងៗ អាចធ្វើប័ណ្ណប្រកាសអំពីអាយភីអឹម (IPM)សម្រាប់ដាក់តាំងបង្ហាញនៅជុំវិញភូមិ ។

## ភ្ញៀវនៅក្នុងសហគមន៏

កសិករក្នុងភូមិ អ្នកជំនាញកសិកម្ម និងមន្រ្តីអភិរក្សអាចត្រូវបានអញ្ជើញអោយមកចូលរួមនៅសាលារៀន ដើម្បីនិយាយសំណេះសំណាលជាមួយសិស្សានុសិស្សអំពីបទពិសោធន៏ក្នុងការអនុវត្ត "អាយភីអឹម" (IPM) នៅក្នុងចំការដំណាំរបស់ពួកគេ ។ សិស្សានុសិស្សអាចបង្កើតបញ្ជីសំណួរសម្រាប់ធ្វើការសម្ភាសន៏ (សួរ) ជាដំបូង ហើយសិស្សម្នាក់ ឬពីរនាក់ចាប់ផ្តើមសម្ភាសន៏បន្តទៀត ដោយមានសំនួរ និងចម្លើយក្នុងរយៈពេលមួយ ដែលនៅទីនោះសិស្សទាំងអស់អាចសួរជាសំនួរ ។

